រស្មីកម្ពុជា ចេញប្រចាំថ្ងៃ

ថ្ងៃ ព្រហស្បតិ៍ ទី 20 ខែ មករា ឆ្នាំ 2005

# តុលាការសម្រេចតម្កល់បណ្ដឹងលោកសមរង្ស៊ីប្ដឹងសម្ដេចហ៊ុន សែន ទុកឥតចាត់ការ

ភ្នំពេញ : លោកយេត ចរិយា ព្រះរាជអាជ្ញារងអមតុលាការក្រុងភ្នំពេញបានសម្រេចចេញដីកាតម្កល់បណ្ដឹងលោកសមរង្ស៊ីប្ដឹងសម្ដេចនាយករដ្ឋមន្ត្រីហ៊ុន សែន ទុកឥតចាត់ការដោយសម្អាងចំណុចគ្មានវិមតិសង្ស័យថា សម្ដេចហ៊ុន សែននាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាជាប់ពាក់ព័ន្ធនឹងមនុស្សឃាតគិតទុកជាមុនប្រព្រឹត្តកាលពីថ្ងៃទី៣០ខែមីនាឆ្នាំ១៩៩៧នោះទេ ។ ទន្ទឹមនេះតុលាការបានបំបែកសំណុំរឿងនេះមួយផ្សេងទៀតដោយបានចោទប្រកាន់ជនមិនស្គាល់មុខ ដែលទទួលខុសត្រូវក្នុងអំពើនេះពីបទភេរវកម្មវិញ ។

លោកសោម ច័ន្ទឌីណា មេធាវីការពារលោកសមរង្ស៊ីបានបញ្ជាក់ប្រាប់រស្មីកម្ពុជានៅរសៀលថ្ងៃទី១៩ខែមករាឆ្នាំ២០០៥ថា លោកយេត ចរិយា ព្រះរាជអាជ្ញារងអមតុលាការក្រុងភ្នំពេញដែលកាន់សំណុំរឿងលោកសមរង្ស៊ីប្ដឹងសម្ដេចហ៊ុន-សែនពីបទសមគំនិតក្នុងអំពើមនុស្សឃាតគិតទុកជាមុនដោយភ្ជាប់ព្រឹត្តិ-ការណ៍ផ្ទុះគ្រាប់បែកនៅមុខរដ្ឋសភាកាលពីថ្ងៃទី៣០ខែមីនាឆ្នាំ១៩៩៧ ជាដើមចូលក្នុងបណ្ដឹងនេះ បានសម្រេចកាលពីថ្ងៃទី១២ខែមករាឆ្នាំ២០០៥ចេញលិខិត៣ដាច់ដោយឡែកៗពីគ្នាដែលលោកបានទទួលនៅថ្ងៃទី១៥ខែមករាឆ្នាំ២០០៥ ។

លោកសោម ច័ន្ទឌីណា បានអះអាងថា លិខិតទាំង៣នោះមានលិខិតជូនដំណឹងដល់ដើមបណ្ដឹងស្ដីអំពីការសម្រេចតម្កល់រឿងទុកឥតចាត់ការ លិខិតមួយទៀតជាដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ និងលិខិតចុងក្រោយគឺជាលិខិតបំបែកសំណុំរឿងនេះមួយផ្សេងទៀត ដោយសម្រេចចោទប្រកាន់ជនមិនស្គាល់មុខពីបទភេរវកម្មប្រព្រឹត្តកាលពីថ្ងៃទី៣០ខែមីនាឆ្នាំ១៩៩៧ ហើយបញ្ជូនទៅឱ្យចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញចាត់ការបន្តតាមនីតិវិធី ។

លោកសោម ច័ន្ទឌីណា បានបន្តថា ការសម្រេចចេញដីកានេះដោយសារលោកយេត ចរិយាបានសម្អាងលើចំណុចគ្មានវិមតិសង្ស័យថា សម្ដេចហ៊ុន សែននាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាជាប់ពាក់ព័ន្ធនឹងមនុស្សឃាតគិតទុកជាមុនប្រព្រឹត្តកាលពីថ្ងៃទី៣០ខែមីនាឆ្នាំ១៩៩៧នោះទេ ។ ម្យ៉ាងទៀតតុលាការក៏បានបំបែកសំណុំរឿងនេះទៅចោទប្រកាន់ជនមិនស្គាល់មុខឱ្យទទួលខុសត្រូវចំពោះបញ្ហានេះវិញហើយ ។ ដូច្នេះបានសបញ្ជាក់ឱ្យឃើញថា តុលាការបានផ្ដាច់សំណុំរឿងនេះចេញពីសម្ដេចហ៊ុន សែនដោយពុំមានជាប់ពាក់ព័ន្ធអ្វីទៀតឡើយ ។

លោកសោម ច័ន្ទឌីណា បានបញ្ជាក់ថា ចំពោះបញ្ហានេះក្នុងនាមជាមេធាវីលោកពុំទាន់សម្រេចចិត្តថាប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចនេះឬយ៉ាងណានៅឡើយទេ ព្រោះត្រូវរង់ចាំស្ដាប់ការសម្រេចពីលោកសមរង្ស៊ីដែលជាដើមបណ្ដឹងជាមុនសិន ប៉ុន្តែទោះបីជាយ៉ាងណាក្ដី ក៏ការប្ដឹងឧទ្ធរណ៍នេះពុំទាន់ហួសពេលនៅឡើយដែរ ព្រោះតាមច្បាប់កំណត់គឺមានរយៈពេល៦០ថ្ងៃឯណោះ ។

គួររំលឹកថា កាលពីថ្ងៃទី២ខែកុម្ភៈឆ្នាំ២០០៤កន្លងទៅនេះ លោកសមរង្ស៊ីបានដាក់ពាក្យបណ្ដឹងប្ដឹងសម្ដេចហ៊ុន សែនពីបទសមគំនិតក្នុងអំពើមនុស្សឃាតគិតទុកជាមុន ដោយភ្ជាប់ព្រឹត្តិការណ៍ផ្ទុះគ្រាប់បែកនៅមុខរដ្ឋសភាកាលពីថ្ងៃទី៣០ខែមីនាឆ្នាំ១៩៩៧ដែលបណ្ដាលឱ្យស្លាប់បាត់បង់ជីវិតយ៉ាងតិច១៦នាក់ និងរងរបួសជាង១០០នាក់ ។ តែនៅក្រោយមកលោកសមរង្ស៊ីបានអំពាវនាវឱ្យដោះស្រាយជាកញ្ចប់នូវបណ្ដឹងរបស់លោកប្ដឹងសម្ដេចហ៊ុន សែននិងបណ្ដឹងសម្ដេចហ៊ុន សែនប្ដឹងលោកពីបទបរិហារកេរ្តិ៍និងជេរប្រមាថ ។ ស.រិទ្ធ